ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...........សហវ.......

ថ្ងៃ.......ខែ....... ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១៩

**ជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីសំណើអនុញ្ញាតឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត គ្រប់គ្រងនិងអនុវត្តថវិកាដូចថវិកាដំណើរការសាលារៀនចាប់ពីឆ្នាំ២០១៩ តទៅ។

**យោង៖** លិខិតលេខ៧៧២ អយក.ហវ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាបថា៖ ឆ្លើយតបទៅនឹងសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឱ្យការអនុវត្តថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត មានប្រសិទ្ធភាព និងជួយជំរុញដល់ការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការងារបច្ចេកទេសមួយចំនួនដូចខាងក្រោម៖

I. សម្រាប់ឆ្នាំថវិកា២០១៩៖

ក-នីតិវិធីអនុវត្តថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត មានដូចខាងក្រោម៖

១- អនុញ្ញាតឱ្យមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ធ្វើការគ្រប់គ្រងនិងអនុវត្តថវិកា ដូចថវិកាដំណើរការសាលារៀន តាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន (បុរេប្រទាន) ប្រចាំត្រីមាស

២-អនុញ្ញាតឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ អនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន ១០០% ដោយធ្វើការសម្រួលនីតិវិធីមួយចំនួនដូចខាងក្រោម៖

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំតារាងបែងចែកឥណទានថវិកាតាមការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) រួចបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត។ តារាងបែងចែកខាងលើត្រូវចាត់ទុកជាតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានដោយស្វ័យប្រវត្តិ ហើយរតនាគាររាជធានី ខេត្ត ត្រូវបង្វែរប្រាក់រជ្ជទេយ្យបុរេប្រទាន ស្មើនឹងទឹកប្រាក់១ជុំបង្វិល ចូលគណនីចរន្តជាប្រាក់រៀល របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ នៅតាមសាខាធនាគារអេស៊ីលីដា ភីអិលស៊ី
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរៀបចំស្នើសុំតែងតាំងរជ្ជទេយ្យករបុរេប្រទានរងនៅតាមការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ តាមរយៈសេចក្តីសម្រេចរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីអាចកាន់កាប់ប្រាក់រជ្ជទេយ្យបុរេប្រទាន និងកិច្ចបញ្ជិកា
- ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយរក្សាទុកសក្ខីបត្រចំណាយច្បាប់ដើមនៅអង្គភាពរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវរួសរាន់រៀបចំបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ឱ្យបានទាន់ពេលវេលា ទៅតាមចំនួនរបាយការណ៍ចំណាយថវិកាពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌដែលទទួលបាន ដោយពុំចាំបាច់រង់ចាំប្រមូលផ្ដុំបូកសរុបជាមួយរបាយការណ៍របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌផ្សេងៗទៀត ដែលមានភាពយឺតយ៉ាវនោះទេ។ ការបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ត្រូវធ្វើឡើងមិនលើសពីរយៈពេល៣ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានរបាយការណ៍ចំណាយថវិកាពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវផ្ដល់ទិដ្ឋាការរួចរតនាគាររាជធានី ខេត្ត ត្រូវទូទាត់បំពេញបេឡារជ្ជទេយ្យបុរេប្រទានដោយបង្វែរសាច់ប្រាក់ចូលគណនីធនាគាររបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ តាមអាណត្តិនិយ័តកម្មនិងរបាយការណ៍ចំណាយខាងលើ
- នាពេលដំណាច់ឆ្នាំ ក្នុងករណីមានប្រាក់រជ្ជទេយ្យបុរេប្រទាននៅសល់ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវ÷(១)- យកប្រាក់ដែលនៅសល់នោះបង់ចូលគណនីរតនាគាររាជធានី ខេត្តនៅធនាគារ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី និង (២)- ត្រូវរួសរាន់រៀបចំរបាយការណ៍ចំណាយថវិកាបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីបោះផ្សាយអាណត្តិនិយ័តកម្មទូទាត់ជម្រះបញ្ជីរជ្ជទេយ្យបុរេប្រទានឱ្យបានទាន់ក្នុងឆ្នាំថវិកា។

**ខ- បញ្ហាប្រឈមក្នុងរយៈពេលអន្តរកាល÷** សម្រាប់កិច្ចប្រតិបត្តិការចំណាយថវិកាឆ្នាំ២០១៩ ផ្អែកតាមបញ្ហាប្រឈមជាក់ស្ដែង អង្គភាពដែលពាក់ព័ន្ធត្រូវសហការដោះស្រាយតាមករណីនីមួយៗ ដូចខាងក្រោម÷

**១- ករណីមិនទាន់បានបើកផ្ដល់ថវិកា÷** ត្រូវអនុវត្តតាមចំណុច “ក” ខាងលើ

**២- ករណីបានបើកផ្ដល់ថវិកាតាមនីតិវិធីបើកផ្ដល់សាច់ប្រាក់មុន (បុរេប្រទាន)÷** មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត បានបើកប្រាក់មុនរួច ១ឆមាស ដូច្នេះត្រូវរៀបចំតារាងកម្មវិធីចំណាយសាច់ប្រាក់តាមត្រីមាស ដើម្បីបន្តបើកប្រាក់សម្រាប់ត្រីមាសទី៣។ **ចំពោះករណីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ,** មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តត្រូវរៀបចំតារាងបែងចែកឥណទានតាមការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ តាមចំណាត់ថ្នាក់សេដ្ឋកិច្ច (ជំពូក គណនី និងអនុគណនី) ហើយអង្គភាពពាក់ព័ន្ធត្រូវសហការកែសម្រួលកិច្ចបញ្ជិកាគណនេយ្យពីការបើកផ្ដល់តាមបុរេប្រទាន (គណនី១៥០៥) មកជា ការបើកផ្ដល់តាមរជ្ជទេយ្យបុរេប្រទាន (គណនី១៤០២) វិញ។ ការបើកប្រាក់មុនរួច ១ឆមាស ស្មើនឹងទឹកប្រាក់២ជុំបង្វិលនៃរជ្ជទេយ្យបុរេប្រទាន ដូច្នេះ ការទូទាត់រជ្ជទេយ្យបុរេប្រទានក្នុងទំហំទឹកប្រាក់១ជុំបង្វិល គឺមិនមានការបំពេញបេឡារជ្ជទេយ្យបុរេប្រទាននោះទេ លុះត្រាតែចំនួនទឹកប្រាក់ទូទាត់រជ្ជទេយ្យបុរេប្រទានឈានចូលជុំបង្វិលទី២សិនទើបរតនាគាររាជធានី ខេត្ត ធ្វើការបំពេញបេឡារជ្ជទេយ្យបុរេប្រទានបន្ថែម។

**៣- ករណីបានបើកផ្ដល់ថវិកាតាមនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន÷** ត្រូវកែសម្រួលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដោយដកឥណទានរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ **ចំពោះករណីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត** ដែលពុំទាន់ធ្វើការទូទាត់បំពេញបេឡារជ្ជទេយ្យបុរេប្រទាន, អង្គភាពពាក់ព័ន្ធត្រូវសហការកែសម្រួលកិច្ចបញ្ជិកាគណនេយ្យពីការបើកផ្ដល់តាមរជ្ជទេយ្យបុរេប្រទាន (គណនី១៤០២) មកជា ការបើកផ្ដល់តាមបុរេប្រទាន (គណនី១៥០៥) វិញ។ ដោយឡែក ករណីដែលមិនអាចកែសម្រួលកិច្ចបញ្ជិកាបានដោយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត បានទូទាត់បំពេញបេឡារជ្ជទេយ្យបុរេប្រទានរួចហើយ នោះគឺផ្ដល់ភាពទន់ភ្លន់ឱ្យមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត អាចជ្រើសរើសជម្រើសណាមួយ នៃជម្រើស២ រួមមាន÷

ជម្រើសទី១-ដោយបានអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទាន ២ត្រីមាស (២ជុំបង្វិល) រួចហើយ ដូច្នេះនៅសល់ ២ត្រីមាសទៀត ត្រូវរៀបចំអនុវត្តតាមនីតិវិធីបើកផ្តល់សាច់ប្រាក់មុន (បុរេប្រទាន) ដូចថវិកាដំណើរការសាលារៀន ចាប់ពីត្រីមាសទី៣ ដោយត្រូវកែសម្រួលតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន និងរៀបចំផែនការចំណាយប្រចាំត្រីមាសផងដែរ និងជម្រើសទី២-អាចបន្តអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទានរហូតដល់ដំណាច់ឆ្នាំថវិកា ដោយរក្សាសក្ខីបត្រចំណាយនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត។ ដោយឡែកសម្រាប់**ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ** គឺអាចបន្តអនុវត្តចំណាយរជ្ជទេយ្យបុរេប្រទានរហូតដល់ដំណាច់ឆ្នាំថវិកា២០១៩។

**II- សម្រាប់ឆ្នាំថវិកា២០២០ តទៅ÷**

អាស្រ័យដោយមានការគ្រោងផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ទៅឱ្យរដ្ឋបាលក្រុង ស្រុក ដូច្នេះករណីមានការធ្វើសមាហរណកម្មផ្ទេរមុខងារការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ឱ្យស្ថិតនៅក្រោមរដ្ឋបាលក្រុង ស្រុក នោះការអនុវត្តថវិការបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្ត ឬ បច្ចុប្បន្នភាពនៃលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ច ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

<u>ចម្លងជូន÷</u>

- -អគ្គនាយកដ្ឋានរតនាគារជាតិ
- -អគ្គនាយកដ្ឋានថវិកា
- -គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
- -គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

  *"ដើម្បីអនុវត្ត"*
- -ឯកសារ-កាលប្បវត្តិ